# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## ក្រោមប្រធានបទ៖ ការកាត់ទោសខ្មែរក្រហមស្ថិតនៅក្នុងក្របខណ្ឌនយោបាយ តើមានប្រយោជន៍ខ្លះឬទេ ?

**Website: www.hoksavann.org**

ថ្ងៃទី១ សីហា ២០១០



ពាក្យថា«យុត្តិធម៌» ប្រែថាភាពត្រឹមត្រូវ ភាពពុំលំអៀងដោយអគតិធម៌ណាមួយ មានលំអៀងព្រោះស្រឡាញ់ឬស្អប់ជាដើម ។ ជនណាធ្វើខុសត្រូវតែយកមកកាត់ទោសតាមច្បាប់របស់រដ្ឋ ។ ចំពោះការកាត់ទោសខ្មែរក្រហម តាមកិច្ចព្រមព្រៀងរបស់រាជរដ្ឋាភិបាលខ្មែរនិងអង្គការសហប្រជាជាតិ គឺកាត់ទោសចំពោះខ្មែរក្រហមដែលទទួលខុសត្រូវជាន់ខ្ពស់ប៉ុណ្ណោះ ។ ការកាត់ទោសដោយកំណាត់ប្រភេទមនុស្សដូច្នេះ ឈ្មោះថាកាត់ទោសដោយផ្លូវនយោបាយ ។ អំពើឧក្រិដ្ឋកម្មនេះពុំមែនតែខ្មែរក្រហម គឺវាពាក់ព័ន្ធទៅជនបរទេសផង ។ ខ្មែរក្រហមជាកូនចៅរបស់ចិនកុម្មុយនិស្ត ពេលខ្មែរក្រហមមានជ័យជំនះ ចិនកុម្មុយនិស្តនៅតែបន្តគ្រប់គ្រងលើខ្មែរក្រហមជាបន្តទៅទៀត ។ ធម្មតាបញ្ហានយោបាយដែលមានការប្រឆាំងគ្នាដ៏សាហាវ រហូតមានការកាប់សម្លាប់ពលរដ្ឋខ្មែរគួរឲ្យរន្ធត់ដូចនេះ បើប្រៀបមកល្ខោន តែងមានទីប្រឹក្សា អ្នកនិពន្ធរឿង អ្នកដឹកនាំរឿង និងអ្នកដើរតួរ ។ តើរឿងខ្មែរក្រហម អ្នកណាជាទីប្រឹក្សានៅពីក្រោយខ្នង អ្នកណាជាអ្នកតែងរឿងនេះ ហើយអ្នកណាជាអ្នកដឹកនាំរឿងនេះពិតប្រាកដ ។ បើកាត់ទោសតែតួរង តួឯកមិនកាត់ទោស អ្នកតែងរឿងនិងអ្នកដឹកនាំរឿងមិនកាត់ទោស ព្រមទាំងអ្នកនៅពីក្រោយខ្នងមិនកាត់ទោស តើការកាត់ទោសខ្មែរក្រហមមានន័យដូចម្តេច ? ។

ការកាត់ទោសមនុស្សធ្វើខុស ដែលប៉ះពាល់ដល់សិទ្ធិមនុស្ស តើព្រះពុទ្ធសាសនាមាននិយាយដូចម្តេច ? ពិតមែនតែព្រះពុទ្ធសាសនាពោលថា ពៀរពុំអាចរម្ងាប់ដោយតបពៀរ ប៉ុន្តែការប្រឹងប្រែងរកយុត្តិធម៌ ព្រះពុទ្ធពុំបានហាមឡើយ ។ បានសេចក្តីថា ច្បាប់ជាអ្នកកាត់ទោស ពុំមែនអ្នករងគ្រោះកាត់ទោសឡើយ ។ ប្រៀបដូចព្រះសង្ឃព្រះពុទ្ធសាសនាប្រព្រឹត្តខុសវិន័យ ព្រះវិន័យធរសង្ឃកាត់សេចក្តីតាមកំហុស ដែលមានចែងក្នុងព្រះវិន័យ ។ ផលប្រយោជន៍នៃការកាត់ទោស គឺផ្តន្ទាទោសដល់អ្នកប្រព្រឹត្តខុសឲ្យកែខ្លួន និងឈប់ប្រព្រឹត្តធ្វើអំពើអាក្រក់នេះតទៅទៀត ។ ផលប្រយោជន៍មួយទៀត គឺជួយលើកតម្កើងអ្នកប្រព្រឹត្តល្អ និងដើម្បីការពារអ្នកប្រព្រឹត្តល្អ កុំឲ្យអ្នកប្រព្រឹត្តអាក្រក់បៀតបៀនតទៅទៀតផង ។

ការកាត់ទោសខ្មែរក្រហមពេលនេះ ទោះបីពុំមានយុត្តិធម៌ពេញបរិបូណ៌ក៏ដោយ ក៏មានប្រយោជន៍មួយដ៏សំខាន់ គឺរកយុត្តិធម៌ជូនអ្នករងគ្រោះ ។ អ្នករងគ្រោះរហូតដល់ស្លាប់ចង់ឲ្យគេដឹងឮពាក្យថា ស្លាប់ដោយអយុត្តិធម៌ដោយគ្មានកំហុស ។ ចង់បានពាក្យនេះ ព្រោះជៀសវាងកុំឲ្យអ្នកសម្លាប់គេចមិនទទួលខុសត្រូវផង និងកុំឲ្យកំហុសដល់អ្នកស្លាប់ដែលគ្មានកំហុសផង ។

មេខ្មែរក្រហមឈ្មោះខៀវ-សំផន, អៀង-សារីជាដើម កាលនៅក្រៅវង់ក្រចកសេះតែងពោលថា ខ្មែរស្លាប់យ៉ាងច្រើននេះ ពុំមែនខ្មែរក្រហមសម្លាប់ទេ គឺស្លាប់ដោយអង្គការយួនបង្កប់ ។ មេគុកទួលស្លែងឈ្មោះឌុច នៅក្នុងវង់ក្រចកសេះក៏មិនឮមេពេជ្ឈឃាតនេះចោទថាយួនដែរ ។ យើងចាំស្តាប់មើលតទៅទៀតនូវផែនការ០០២ តើខៀវ-សំផន, អៀង-សារី, អៀង-ធីរិទ្ធ និងនួន-ជា នៅតែចោទយួនថា ខ្មែរស្លាប់ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ដោយអង្គការយួនបង្កប់ ដូចខ្លួននៅក្រៅវង់ក្រចកសេះឬទេ ? មេខ្មែរក្រហមទាំង៤នេះ ត្រូវមានសេចក្តីក្លាហានឆ្លើយតាមការពិត បើធ្វើពហីការមិនឆ្លើយ ក៏ពុំអាចរួចខ្លួនឡើយ ព្រោះឯកសារភស្តុតាងមានគ្រប់គ្រាន់ហើយ ។ បញ្ហាមួយទៀត បើចាប់ខ្មែរក្រហម៥នាក់ទៀតមកកាត់ទោសតាមសំណើរបស់សហព្រះរាជអាជ្ញាអង្គការសហប្រជាជាតិ យើងមើលឃើញថា នឹងមិនមែនខ្មែរក្រហមណារត់ចូលព្រៃ ដើម្បីការពារមេខ្មែរក្រហមទាំងនេះឡើយ ។

បច្ចុប្បន្ននេះនិងទៅអនាគត យើងនៅតែបារម្ភថា មេខ្មែរក្រហមរបស់ប៉ុល-ពតនៃម៉ៅ-សេទុង បានត្រូវរលត់រលាយហើយ ប៉ុន្តែមាគ៌ារបស់ខ្មែរក្រហមនៅតែត្រូវគេយកមកអនុវត្តនៅប្រទេសកម្ពុជា ដោយយកចង្អេរប្រជាធិបតេយ្យបាំងមុខ ។ បើដូច្នេះពិតមែន ប្រជាពលរដ្ឋខ្មែរនៅតែមានសេចក្តីទុក្ខវេទនា និងគ្មានសិទ្ធិសេរីភាពតទៅទៀត ។ យើងសូមបួងសួងសូមពលរដ្ឋខ្មែររស់នៅជាអ្នកជា រស់នៅជាម្ចាស់វាសនានៃប្រទេសរបស់ខ្លួន ដោយគ្មានអំណាចណាមួយសង្កត់សង្កិន ។

❊ ❊

❊